# សេចក្ដីប្រកាសព័ត៌មានរួម

*សហរដ្ឋអាមេរិក* *ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៧*

អង្គការ-សមាគម *ហត្ថលេខីខាងក្រោម* សូមថ្កោលទោសសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស និងសម្ដេចព្រះសង្ឃនាយក នន្ទ ង៉ែត និងភាគីសមគំនិតនឹងគ្នាពាក់ព័ន្ធទាំងអស់ ។

នៅថ្ងៃទី៣០ មិថុនា ២០០៧ ព្រះភិក្ខុ ទឹម សាខន ចៅអធិការវត្តភ្នំដិនខាងជើង ភូមិផ្សារ ឃុំភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ ព្រះរាជាណាចក្រកម្ពុជា ត្រូវបាននិមន្តទៅប្រជុំនៅសាលាគណខេត្ត ។ ព្រះអង្គ ក៏ត្រូវបានចាប់ផ្សឹក ផ្ដុយនឹងឆន្ទៈរបស់ព្រះអង្គ និងវិន័យព្រះពុទ្ធសាសនា បញ្ជាដោយសម្ដេចព្រះសង្ឃនាយក នន្ទ ង៉ែត និងបានឯកភាពដោយសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស ហើយមានមនុស្សមួយក្រុមពង្រត់ព្រះអង្គបញ្ជូនទៅប្រទេសយួននៅថ្ងៃដដែល ។

១០ថ្ងៃហើយ តាំងពីថ្ងៃគេចាប់ផ្សឹកព្រះតេជព្រះគុណ ទឹម សាខន ។ សុវត្ថិភាព សន្តិសុខ និងសុខុមាលភាពរបស់ព្រះអង្គ មកដល់ពេលនេះនៅតែពុំទាន់ដឹងច្បាស់លាស់នៅឡើយ ។

សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្ដេចព្រះសង្ឃនាយក នន្ទ ង៉ែត ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឃុន ហាំង និងជនពាក់ព័ន្ធទាំងឡាយ ត្រូវតែ :

១-នាំយកព្រះភិក្ខុ ទឹម សាខន មកប្រទេសកម្ពុជាវិញ បំបួស និងប្រគេនឋានភាពជាព្រះចៅអធិការដល់ព្រះអង្គវិញ។

២-បញ្ឈប់ការគំរាមកំហែងចំពោះព្រះភិក្ខុសង្ឃ ក្នុងការបញ្ចេញមតិនានា ប្រយោជន៍អភិវឌ្ឍន៍ប្រទេសជាតិ ។

៣-លុបចោលសង្ឃប្រកាស ចុះនៅថ្ងៃទី០៨ មិថុនា ២០០៧ ដែលមាន ៦-ប្រការហាមប្រាមព្រះភិក្ខុសង្ឃមិនឱ្យចូលរួមក្នុងធម្មយាត្រា បាតុកម្ម កូដកម្ម និងកុបកម្ម ។

យើង សូមអំពាវនាវដល់រាជរដ្ឋាភិបាល រដ្ឋសភានិងព្រឹទ្ធសភាកម្ពុជា រដ្ឋាភិបាល រដ្ឋសភានិងព្រឹទ្ធសភាសហរដ្ឋអាមេរិក អង្គការសហប្រជាជាតិ ទូតានុទូតប្រចាំកម្ពុជា សហគមន៍អន្តរជាតិ និងបណ្ដាវត្តព្រះពុទ្ធសាសនា ព្រះមេត្តានិងមេត្តាជួយអន្តរាគមន៍ឱ្យព្រះភិក្ខុ ទឹម សាខន បាននិមន្តត្រឡប់ទៅវត្តរបស់ព្រះអង្គវិញ ។

ទំនាក់ទំនង :

គិម ប.ម. សគល

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង

ទូរស័ព្ទ : ៤០១-៦៩៩-៥៣២០, អ៊ីមែល : kkcpressoffice@yahoo.com

ឈួត សុវណ្ណ

ប្រធានសមាគមខ្មែរនៃរដ្ឋរ៉ូដអៃឡិនដ៍

ទូរស័ព្ទ : ៤០១-៣៦៩-៩០៩៣

# **Joint Press Release**

*United States* *July 9, 2007*

We, *The Undersigned organizations*, strongly condemn the cruel act committed by the highest Buddhist figures in the Kingdom, Great Supreme Patriarch Tep Vong, Supreme Patriarch Non Nget and the involved party.

On June 30, 2007 Chief Abbot Tim Sakhorn, Buddhist monk of Wat Phnom Den North, Phsa village, Phnom Den commune, Kirivong district, Takeo province, Kingdom of Cambodia was invited to attend a meeting held at the provincial Buddhist office. His Venerable Tim Sakhorn was forcibly defrocked (disrobed) or leave monkhood against his will and the Buddhist teaching. On the same day, he was abducted by a group of people and transported swiftly to Vietnam.

The injustice committed upon the venerable Tim Sakhorn was ordered by the Supreme Buddhist Patriarch Non Nget and concurred by the Great Supreme Patriarch Tep Vong of Cambodia.

It has been 10 days since His Venerable Tim Sakhorn forced to defrock and whereabouts his location is unknown. His safety, security and health remain in the dark.

The Great Supreme Patriarch Tep Vong and Supreme Patriarch Non Nget, Senior Minister and Minister of Cult and Religion Ministry Khun Haing and involved party must:

- Return safely, re-ordain, and restore Chief Abbot status of His Venerable Tim Sakhorn.
- Cease all threats and intimidations of further illegal defrocking and kidnapping upon the Buddhist monks against their will and rules, especially the 11 Khmer Kampuchea Krom Buddhist leaders and non-governmental leaders and human right activists.
- Rescind the June 8, 2007 6-Point Decree prohibiting Buddhist monks from participating in Dharma Walk (Peace March), strike, rally, and demonstration.
- Buddhist leaders or monks that forced other monks to defrock against their will and rule must resign to save Buddhism.

We appeal to Cambodian Royal Government, Parliament and Senate, U.S. Government, House of Representatives, and Senate, United Nations, international Buddhist organizations and non-governmental organizations to help Ven. Tim Sakhorn returns to Cambodia.

Contact:

Kim P.M. Sakal
Executive Director
The Khmer Kampuchea Krom Community-North America
401-699-5320, E-Mail: kkcpressoffice@yahoo.com

Chhouk Savann
Board President
The Cambodian Society of Rhode Island
401-451-4933